THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២២

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានឈានដល់ចំណុចសំខាន់មួយក្នុងការខិតខំប្រឹងប្រែងបន្តរបស់ក្រសួងក្នុងការផ្តល់ឱ្យសិស្សទាំងអស់នូវបរិយាកាសសិក្សាក្នុងសតវត្សទី ២១ ដែលពួកគេត្រូវការដើម្បីទទួលជោគ ជ័យ។ នៅក្នុងកិច្ចប្រជុំរបស់ក្រសួងកាលពីយប់មិញ ក្រុមប្រឹក្សាអប់រំបានអនុម័តលើកិច្ចសន្យាសម្រាប់អង្គការពីរដែលនឹងសហការជាមួយមន្ត្រីរបស់ក្រសួងលើដំណើរការរៀបចំផែនការអាគារ [Facilities Planning Process (FPP)] ថ្មី ដើម្បីចាប់ផ្តើមនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២២។

ដំណើរការរៀបចំផែនការអាគារ (FPP) គឺជាសមាសភាគដ៏សំខាន់ចំពោះវិធីសាស្រ្តរៀបចំផែនការរបស់ក្រសួង ដើម្បីផ្តល់នូវដំណោះស្រាយជាក់ស្តែងចំពោះបញ្ហាអាគារ និងការប្រើប្រាស់សាលា។ តាមរយៈនៃការចែករំលែកទិន្នន័យ និងតាមការជួបផ្ទាល់ និងការចូលរួមពីសហគមន៍ និងទំនាក់ទំនង តាមអ៊ីនធឺណិត ក្រសួងអប់រំនឹងស្នើសុំមតិយោបល់ពីសហគមន៍សាលាអំពីជម្រើសដែលមានសមធម៌សម្រាប់អនាគតនៃបរិយាកាសសិក្សារបស់ក្រសួង។ ជម្រើសទាំងនេះនឹងនាំទៅរកអនុសាសន៍ចុងក្រោយដែលនឹងពន្យល់បង្ហាញដល់ក្រុមប្រឹក្សាភិបាលនៅនិទាឃរដូវ ២០២៣ ហើយនៅទីបំផុតផ្តល់ដំណឹងដល់ ផែនការធំនៃការរៀបចំអាគារ (Facilities Master Plan) របស់ក្រសួង ដែលជាវិធីសាស្រ្តដែលមានរយៈពេលយូរ ឆ្ពោះទៅមុខ ដើម្បីកំណត់អាទិភាពក្នុងការចំណាយលើការវិនិយោគសម្រាប់អាគារ និងធានាថាកន្លែងសិក្សាទាំងអស់ត្រូវបានរៀបចំដោយមានឧបករណ៍ និងប្រដាប់ប្រដាដែលសិស្សត្រូវការដើម្បីឲ្យមានជោគជ័យ។

ក្នុងរយៈពេលដប់បីខែបន្ទាប់ សហគមន៍សាលាទាំងអស់នឹងត្រូវបានវាយតម្លៃជាផ្នែកនៃដំណើរការនេះ។ យោងទៅលើការវាយតម្លៃទាំងនោះ សាលាអាចចូលរួមក្នុងការសន្ទនាដែលដឹកនាំដោយអ្នកសម្របសម្រួល ដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ដំណឹងអំពីអនុសាសន៍ចុងក្រោយ។ អង្គការ WXY Studios នឹងដឹកនាំឲ្យមានការចូលរួមពីសហគមន៍ដ៏ទូលំទូលាយ នៅពេលដែលអង្គការ Skai Blue Media នឹងផ្តល់ការគាំទ្រវិធីសាស្រ្តទំនាក់ទំនង ដើម្បីឱ្យសហគមន៍សាលាទទួលព័ត៌មានក្នុងរយៈពេលនៃដំណើរការនេះ។

ដំណើរការរៀបចំផែនការអាគារ (FPP) ពង្រីកការងារដែលកំពុងដំណើរការ ដើម្បីកែលម្អលក្ខខណៈអាគារទូទាំងក្រសួង និងផ្តល់នូវបរិយាកាសសិក្សាដែលប្រកបដោយសមធម៌សម្រាប់សិស្ស**ទាំងអស់**។ វាក៏បង្កើតឡើង និងជំនួសដំណើរការនៃការចូលរួមពីសហគមន៍ដែលបានចាប់ផ្តើមក្រោម ការពិនិត្យផែនការសាលារដ៏ទូលំទូលាយ [Comprehensive School Planning Review (CSPR)] ដែលជាគំនិតផ្តួចផ្តើមដែលត្រូវបានផ្អាកនៅឆ្នាំ ២០២០ ដោយសារជំងឺរាតត្បាត COVID-19។

នៅពេលចាប់ផ្តើមជាផ្លូវការក្នុងខែ មីនា គម្រោងផែនការពេញលេញនឹងត្រូវបានបញ្ចេញ រួមទាំងការកំណត់ពេលវេលាពេញលេញសម្រាប់ផែនការ ដែលមានកាលបរិច្ឆេទ ដែលទិន្នន័យនឹងត្រូវបានបញ្ចេញ ព្រមទាំងព័ត៌មានលម្អិតអំពីដំណើរការចូលរួមពីសហគមន៍។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ដំណើរការរៀបចំផែនការអាគារ (FPP) និងដើម្បីទទួលព័ត៌មានថ្មីៗអំពីគម្រោងការ សូមមើលគេហទំព័រ philasd.org/facilitiesplanning។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite Jr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា